**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ១៣-០២០-០០២

*ថ្ងៃអង្គារ ៩រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣*
*រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០*

# សេចក្តីប្រកាសព័ត៌មាន

បន្ថែមលើវិធានការដែលធនាគារជាតិនៃកម្ពុជាបានដាក់ចេញកាលពីពេលថ្មីៗនេះ ធនាគារជាតិនៃកម្ពុជានឹងដាក់ចេញនូវវិធានការគាំទ្រចំនួន ៥ ដើម្បីផ្តល់សន្ទនីយភាពបន្ថែមដល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ សំដៅរួមចំណែកកាត់បន្ថយផលប៉ះពាល់ពីជំងឺកូវីដ១៩ មកលើសេដ្ឋកិច្ចកម្ពុជា ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម ៖

១/- ពន្យាពេលឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុរក្សាកម្រិតទ្រនាប់ដើមទុនខនស៊ើវេសិន (CCB) ត្រឹម ៥០%

២/- កាត់បន្ថយអត្រាការប្រាក់អប្បបរមានៃប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ចំនួន ០,៥% ចំពោះគ្រប់ឥណប្រតិទាន

៣/- កាត់បន្ថយអត្រាការប្រាក់លើមូលបត្រអាចជួញដូរបាន (NCD) ចារឹកជាប្រាក់រៀលនិងជាដុល្លារអាមេរិក ក្នុងកម្រិតសមស្រប

៤/- កាត់បន្ថយអត្រាប្រាក់បម្រុងកាតព្វកិច្ច (RRR) ពី ៨% ចំពោះប្រាក់រៀល និង ១២,៥% ចំពោះរូបិយប័ណ្ណ មកត្រឹម ៧% ទាំងចំពោះប្រាក់រៀលនិងរូបិយប័ណ្ណ ក្នុងរយៈពេល ៦ខែ ចាប់ពីខែមេសា ឆ្នាំ២០២០ និង

៥/- កាត់បន្ថយកម្រិតអនុបាតក្របខ័ណ្ឌសន្ទនីយភាព (LCR) ក្នុងកម្រិតសមស្រប តាមការចាំបាច់។

ធនាគារជាតិនៃកម្ពុជានឹងបន្តតាមដានយ៉ាងប្រុងប្រយ័ត្នលើស្ថានភាពវឌ្ឍនភាពវិស័យធនាគារ បញ្ហាប្រឈម និងហានិភ័យនានា ដែលអាចកើតឡើងជាយថាហេតុ ក្នុងគោលដៅរក្សានិរន្តរភាពនិងស្ថិរភាពនៃវិស័យធនាគារនិងហិរញ្ញវត្ថុ និងរួមចំណែកគាំទ្រកំណើនសេដ្ឋកិច្ច ប្រកបដោយចីរភាព។

**ទំនាក់ទំនង៖**
ផ្នែកទំនាក់ទំនងធនាគារជាតិនៃកម្ពុជា
លេខទូរស័ព្ទ៖ (៨៥៥) ២៣ ៩៨០ ១៨៦
អ៊ីម៉ែល៖ nbccommunication@nbc.org.kh